-សមាជិកទាំងអស់ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ សហប្រធាន ក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ។

ការរៀបចំការប្រជុំទាំងឡាយរបស់ក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ និងការតាមដានការអនុវត្តនូវផែនការសេចក្តីណែនាំទាំងអស់របស់ខ្លួន ត្រូវបានកំណត់ដោយអគ្គលេខាធិការដ្ឋានទទួលបន្ទុកការងារអតីតយុទ្ធជន ។

មាត្រា ៦ .- រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៧ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ៤៥ អនក្រ.បក
# ស្តីពីការបង្កើតគណៈកម្មការរៀបចំទិវា
# មហោស្រពអង្គរ ឆ្នាំ១៩៩៩-២០០០

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- យោងតាមការចាំបាច់នៃការយានុវត្តភាពបើកឆ្នាំសន្តិភាព ទេសចរណ៍ ឆ្លងដំណាច់សតវត្សទី ២០

## សំរេច

មាត្រា ១ .- បង្កើតគណៈកម្មការរៀបចំទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩-២០០០ មួយដែលមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ស៊ុំ ម៉ានិត រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន

www.pheakdeylaw.com

២-ឯកឧត្តម មិន ឃិន រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង ជាអនុប្រធាន

៣-ឯកឧត្តម ម៉ែន យ៉េន រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាអនុប្រធាន

៤-ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការក្រសួងទេសចរណ៍ ជាអនុប្រធាន

៥-ឯកឧត្តម-គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៦-ឯកឧត្តមអ៊ុង គីមអន រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៧-ឯកឧត្តម អ៊ុំ ដារ៉ាវុឌ្ឍ រដ្ឋលេខាធិការក្រសួងព័ត៌មាន ជាសមាជិក

៨-ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក

៩-ឯកឧត្តម ចាប ញ៉ាលីវុធ អភិបាលខេត្តសៀមរាប ជាសមាជិក

១០-ឯកឧត្តម សេខ នុខ អភិបាលរងរាជធានីភ្នំពេញ ជាសមាជិក

១១-ឯកឧត្តម កែវ សាផល អនុរដ្ឋលេខាធិការអាកាសចរស៊ីវិល ជាសមាជិក

១២-ឯកឧត្តម ស៊ីវ គង់ អគ្គនាយករងអាជ្ញាធរអប្សរា ជាសមាជិក

១៣-ឯកឧត្តម ប៉ាន់ ចន្ត្រា ប្រធានក្រុមហ៊ុនអាកាសចរភូមិន្ទកម្ពុជា ជាសមាជិក

១៤-លោក ឆែម គីមហ៊ាង អគ្គនាយករងក្រសួងសាធារណការនិងដឹកជញ្ជូន ជាសមាជិក

១៥-លោកឧត្តមសេនីយ៍ ស៊ឹម សុផល ប្រធាននាយកដ្ឋានអង្គរក្សក្រសួងមហាផ្ទៃ ជាសមាជិក

១៦-លោក ខៀវ ថាវិកា ប្រធាននាយកដ្ឋានព័ត៌មានទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

**មាត្រា ២ ._** ឆ្លងតាមរយៈទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩ -២០០០ គណៈកម្មការនេះមានបេសកកម្មបង្ហាញជូន ទស្សនារម្មណ៍ជាតិ និង អន្តរជាតិនូវ :

-អត្តសញ្ញាណជាតិខ្មែរតំណវង្សពីអង្គរ

-វប្បធម៌ អារ្យធម៌ដ៏រុងរោចន៍នាសម័យអង្គរ ផ្សារភ្ជាប់និងគោលនយោបាយរបស់រាជរដ្ឋាភិបាល នាបច្ចុប្បន្នក្នុងជំហរលើកកំពស់ :

ក-ការពង្រឹងសន្តិភាព

ខ-ផ្សះផ្សារជាតិ និងបង្រួបបង្រួមជាតិ

គ-សាមគ្គីធម៌ជាតិ និងអន្តរជាតិ

ឃ-ការស្តារវីរភាព កិត្តិយស និងសីលធម៌រស់នៅថ្លៃថ្នូររបស់ប្រជាពលរដ្ឋខ្មែរ

ង-តាមរូបភាព និងខ្លឹមសារនៃទស្សនីយភាពប្រែក្លាយទិវាមហោស្រពនេះអោយទៅជាព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រពិភពលោកមួយសំដៅបំបាត់រាល់ការបង្អាប់បង្ខូចកេរ្តិ៍ឈ្មោះខ្មែរពីសំណាក់បរទេស ក្នុងរយៈពេលកន្លងមកដោយប្តេជ្ញាទទួលខុសត្រូវរាសនាខ្លួនឯងនៅថ្ងៃអនាគត ។

**មាត្រា ៣ ._** ដើម្បីសំរេចនូវបេសកកម្មខាងលើនេះ គណៈកម្មការរៀបចំទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩-២០០០ មានភារកិច្ច ដូចតទៅ ÷

www.pheakdeylaw.com

-បើកអង្គប្រជុំជាញឹកញាប់ដើម្បីពិភាក្សាពិគ្រោះយោបល់ និងបែងចែកភារកិច្ចដែលពាក់ព័ន្ធនឹងជំនាញមុខសញ្ញាជូនសមាជិកទទួលខុសត្រូវរៀងៗខ្លួន

-ធ្វើសារាចរណែនាំស្ដីពីការប្រារព្ធទិវាមហោស្រពឆ្នាំ ១៩៩៩-២០០០

-រៀបចំតារាងប្រធានបទ ខ្លឹមសារ រូបភាពប៉េអាប់ទិវាមហោស្រពនេះ

-បង្កើតអនុគណៈកម្មការមួយចំនួនដើម្បីប្រគល់ភារកិច្ចដោយឡែកតាមភាពចាំបាច់

-តាមដានត្រួតពិនិត្យ កែសម្រួលជាជំហានៗ នូវរាល់សកម្មភាពរបស់ផ្នែកនីមួយៗ

-ជំរុញ និងអំពាវនាវគ្រប់មជ្ឈដ្ឋានជាតិ និងអន្ដរជាតិ ប្រជាជន មហាជន សប្បុរសជន ដើម្បីជួយឧបត្ថម្ភគាំទ្រចំពោះទិវាមហោស្រពនេះ

-ជំរុញអោយមហាជន ទេសចរជាតិ និង អន្ដរជាតិចូលរួមក្នុងទិវាមហោស្រពនេះ អោយបានកុះករ

-ធ្វើវេទិកាកម្មអប់រំដល់ មន្ដ្រីរាជការ នគរបាល កងទ័ព សិស្ស និស្សិត ប្រជាពលរដ្ឋគ្រប់ស្រទាប់ និង ព្រះសង្ឃនៅទូទាំងព្រះរាជាណាចក្រកម្ពុជា អោយជួយជ្រោងខ្ពស់ទិវាមហោស្រពប្រវត្តិសាស្ដ្រនេះ

-ផ្សព្វផ្សាយ និងអំពាវនាវចំពោះសិប្បករខ្មែរអោយខិតខំសាំងស្នាដៃ ផលិតនូវវត្ថុសិល្បៈពាក់ព័ន្ធនិងវប្បធម៌ អារ្យធម៌អង្គរជាពិសេស ប្រជាពលរដ្ឋ ខេត្តសៀមរាបទាំងមូល ដើម្បីលក់យកកំរៃនៅអំឡុងពេលប្រព្រឹត្តទៅនៃមហោស្រពនោះ

-ត្រៀមលក្ខណៈរៀបចំទីលានមុខប្រាសាទអង្គរវត្ត ដើម្បីសំដែង និងប្រារព្ធពិធី

-រកគ្រប់លទ្ធភាពបើកប្រាសាទមួយចំនួនទៀត ដូចជាទីលានជល់ដំរី និងស្រះស្រង់ ជាដើម សំរាប់ធ្វើនិទស្សន៍អំពីឆ្នាំសន្ដិភាព ទេសចរណ៍ ចំពោះមជ្ឈដ្ឋានជាតិ និងអន្ដរជាតិ

មាត្រា ៤ ._ កំណត់យកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៩ ជាថ្ងៃពិធីបើកមហោស្រព ( ថ្ងៃចូលបុណ្យ )

-ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៩ ជាទិវាប្រកាស បិទ / បើកសតវត្ស និង ឆ្នាំ សន្ដិភាព- ទេសចរណ៍ ដោយ សម្ដេចនាយករដ្ឋមន្ដ្រី

-និងថ្ងៃទី ០១ ខែមករា ឆ្នាំ២០០០ ជាថ្ងៃបិទមហោស្រព ។

មាត្រា ៥ ._ គណៈកម្មការជាតិរៀបចំទិវាមហោស្រព ឆ្នាំ១៩៩៩-២០០០ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្ដីការគណៈរដ្ឋមន្ដ្រី ។

មាត្រា ៦ ._ រាល់បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះជាពិសេស អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ ._ រដ្ឋមន្ដ្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ដ្រី រដ្ឋមន្ដ្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ដ្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ដ្រីក្រសួងទេសចរណ៍ រដ្ឋមន្ដ្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សាលាក្រុងភ្នំពេញ គណៈកម្មការរៀបចំបុណ្យជាតិ និងអន្ដរជាតិ រដ្ឋមន្ដ្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

www.pheakdeylaw.com

រាជធានីអេប្បរា និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធិភាព ខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៤៦ អនក្រ.បក

## ស្តីពីការផ្ទេរឥណទាន

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧៨ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នរ/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកា ចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរតំរូវការ និង ផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី